# សុន្ទរកថា
# របស់
# អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីបិទសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ ២០២៣ ក្រោមប្រធានបទ «ចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ ២០៣០ និង ឆ្នាំបន្តបន្ទាប់ទៀត ៖ ការកំណត់មាគ៌ា សម្រាប់វិបុលភាព ប្រកបដោយភាពធន់, និរន្តរភាព និង បរិយាបន្ន»

**សណ្ឋាគារ សុខាភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០២៣, ម៉ោង ១៦:៣០-១៧:១៥**

*ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី, ភ្ញៀវកិត្តិយសទាំងអស់, ជាទីមេត្រី!*

ថ្ងៃនេះ, ខ្ញុំពិតជាមានសេចក្ដីសោមនស្សយ៉ាងក្រៃលែង ដោយបានមកចូលរួមថ្លែងសុន្ទរកថាបិទ ក្នុង **សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ ២០២៣ ក្រោមប្រធានបទ «ចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ ២០៣០ និង ឆ្នាំបន្តបន្ទាប់ទៀត ៖ ការកំណត់មាគ៌ា សម្រាប់វិបុលភាព ប្រកបដោយភាពធន់, និរន្តរភាព និង បរិយាបន្ន»** ដែលត្រូវបានផ្ដួចផ្ដើមរៀបចំឡើង ដោយ **វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា** (CDRI) រួមសហការជាមួយក្រសួង-ស្ថាប័ននានា ជាដៃគូ ។

ផ្អែកតាមរបាយការណ៍សង្ខេបស្តីពីលទ្ធផលសន្និសីទ នៅមុននេះ របស់ **លោកស្រី បណ្ឌិត អេង នេត្រា**, **នាយិកាប្រតិបត្តិ CDRI**, បន្ថែមពីលើខ្លឹមសាររួមដ៏មានសារៈ-ប្រយោជន៍, ខ្ញុំក៏ទទួលបានផងដែរ នូវអារម្មណ៍ និង មនោសញ្ចេតនាដ៏ជ្រាលជ្រៅ អំពីការចូលរួមពិភាក្សារបស់វាគ្មិនទាំងឡាយ ក្នុងអង្គសន្និសីទ ដែលបានប្រព្រឹត្តទៅយ៉ាងផុសផុល, ស៊ីជម្រៅ និង ម៉ត់ចត់ តាមរយៈការចែករំលែក និង ផ្លាស់ប្តូរគំនិត, យោបល់ និង បទពិសោធន៍, ក្នុងស្មារតីស្ថាបនា និង ត្រង់ទៅ-ត្រង់មក, ព្រមទាំងការខិតខំរិះរកមធ្យោបាយនានា សម្រាប់តម្រង់ទិសដល់ការអភិវឌ្ឍកម្ពុជា ឱ្យបានកាន់តែប្រសើរ និង សម្រាប់កសាងមាគ៌ាអនាគតមួយដ៏ត្រឹមត្រូវ ឆ្ពោះទៅសម្រេចបាននូវជោគវាសនារួមរបស់កម្ពុជា ប្រកបដោយក្តីសង្ឃឹមខ្ពស់ ស្របតាមការប្រាថ្នាចង់បាន របស់ប្រជាពល-រដ្ឋកម្ពុជាទូទាំងប្រទេស ។

ជាការពិតណាស់, ដំណើរឆ្ពោះទៅរកការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយភាពធន់, និរន្តរភាព និង បរិយាបន្ន ពុំមែនជាកិច្ចការងាយស្រួល និង អាចកើតមានឡើងដោយឯកឯងនោះឡើយ, តែគឺជាដំណើរវែងឆ្ងាយ ដែលទាមទារឱ្យមានការចូល-រួមជិតស្និទ្ធ ពីគ្រប់តួអង្គពាក់ព័ន្ធទាំងអស់, ការប្តេជ្ញាចិត្តខ្ពស់, កិច្ចសហការស្អិតល្មួត, និង ការតម្កល់ផលប្រយោជន៍ជាតិ ជាធំ, ប្រកបដោយគំនិតច្នៃប្រឌិត, នវានុវត្តន៍ និង ភាពបត់បែន តាមការវិវត្តជាក់ស្តែង ។ អាស្រ័យហេតុនេះ, ការចូលរួមចំណែកនាពេលនេះ គឺជាវិភាគទានមួយដ៏សំខាន់ ដើម្បីឈានទៅសម្រេចបាន នូវ «**ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០**» ក្នុងការប្រែក្លាយកម្ពុជា ទៅជាប្រទេសមានចំណូលខ្ពស់ ដោយឆ្លងកាត់បង្គោលចរនៃការប្រែក្លាយខ្លួន ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ ។ ជាការពិត, ដំណើរលើផ្លូវដ៏វែងឆ្ងាយនេះ គប្បីចាប់ផ្តើមពីការកំណត់ចក្ខុវិស័យឱ្យបានច្បាស់លាស់ជាមុនសិន, ទើបបន្តពីនេះ, យើងទាំងអស់គ្នាអាចប្រមូលធាតុចូលចាំ-បាច់, ស្វែងរកមធ្យោបាយសមស្រប និង ដាក់ចេញនូវយន្តការត្រឹមត្រូវ, ដើម្បីជម្នះឧបសគ្គផងទាំងពួង សំដៅឈានទៅសម្រេចបានតាមចក្ខុវិស័យនោះ ។ ក្នុងន័យនេះ, ខ្ញុំមានជំនឿថា ការរៀបចំសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ ២០២៣ ក្រោមប្រធាន-

បទ «**ចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ ២០៣០ និង ឆ្នាំបន្តបន្ទាប់ទៀត ៖ ការកំណត់មាគ៌ាសម្រាប់វិបុលភាព ប្រកបដោយភាពធន់, និរន្តរភាព និង បរិយាបន្ន**» គឺពិតជាសមស្រប, ទាន់ពេល និង ចំទិសដៅ ។

**ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!**

ក្នុងរយៈពេល ២៥ ឆ្នាំចុងក្រោយ, បន្ទាប់ពីការសម្រេចបាននូវ សុខសន្តិភាពពេញលេញ, ឯកភាពជាតិ និង ឯកភាពទឹកដីទាំងស្រុង តាមរយៈ **នយោបាយឈ្នះ-ឈ្នះ** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវសមិទ្ធផលធំៗ លើគ្រប់វិស័យ, ទាំងនយោបាយ, សង្គម, និង សេដ្ឋកិច្ច, ដែលនាំឱ្យកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មី គួរជាទីមោទនៈបំផុត ។

ពេលនេះ, ដំណើរការកសាងជាតិរបស់កម្ពុជា បានឈានដល់ដំណាក់កាលថ្មីមួយ នៅក្នុងបរិការណ៍នៃពិភពលោក ដែលកាន់តែប្រែប្រួល, លំបាក និង មិនប្រាកដប្រជា ។ ស្របពេលដែលបង្គោលចរ ឆ្នាំ ២០៣០ កាន់តែខិតជិតមកដល់ ពោលគឺ នៅសល់ប្រមាណ ៧ ឆ្នាំទៀតប៉ុណ្ណោះ, ទស្សនអនាគតនៃកំណើនរបស់កម្ពុជា ត្រូវបានបន្តហ៊ុមព័ទ្ធ ដោយហានិភ័យ និង ភាពមិនប្រាកដប្រជាខ្ពស់ ពីកត្តាធំៗខាងក្រៅ មានជាអាទិ៍ ៖ ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ, កំណើនទាបនៃសេដ្ឋកិច្ចសកល ដែលបណ្តាលមកពី សង្គ្រាមពាណិជ្ជកម្ម, ការបន្តរឹតបន្តឹងគោលនយោបាយរូបិយវត្ថុរបស់ប្រទេសអភិវឌ្ឍន៍ ក្នុងការឆ្លើយតបទៅនឹងសម្ពាធអតិផរណា, ការអូសបន្លាយនៃសង្គ្រាមរវាងរុស្ស៊ី និង អ៊ុយក្រែន, ការថមថយនៃកំណើនសេដ្ឋកិច្ចចិន និង បណ្តាប្រទេសអឺរ៉ុប ព្រមទាំងបញ្ហាសង្គ្រាមរវាងអ៊ីស្រាអែល និង ក្រុមហាម៉ាស ដែលទើបផ្ទុះឡើង នាពេលថ្មីៗ ។ លើសពីនេះទៀត, ការប្រែប្រួលអាកាសធាតុ, ដែលជាបញ្ហាប្រឈមរួមរបស់មនុស្សជាតិទាំងមូល, ក៏កំពុងតែបង្កផលប៉ះពាល់អវិជ្ជមាន កាន់តែធ្ងន់ធ្ងរ ផងដែរ ។ ជារួម, ហានិភ័យ និង បញ្ហាប្រឈមទាំងនេះ បាន និង កំពុងបង្កផលប៉ះពាល់លើពាណិជ្ជកម្មអន្តរជាតិ និង លំហូរនៃការវិនិយោគមកក្នុងប្រទេស ដែលអាចយាយីដល់កិច្ចខិតខំប្រឹងប្រែងរបស់យើង ក្នុងការស្តារសេដ្ឋកិច្ចឡើងវិញ ក៏ដូចជាអាចប៉ះទង្គិចផងដែរ ដល់គន្លងនៃការ-

អភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ឆ្ពោះទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ ២០៣០ ។

យ៉ាងណាក៏ដោយ, កម្ពុជានៅតែមានសក្តានុពល និង កាលានុវត្តភាពជាច្រើន, ទាំងខាងក្រៅ និង ក្នុងប្រទេស, សម្រាប់ពន្លឿនការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក្នុងនោះរួមមាន ៖ ១).ការផ្លាស់ប្តូរកាន់តែលឿននៃច្រវាក់ផលិតកម្ម ពីតំបន់ និង ប្រទេសផ្សេងៗ មកកាន់អាស៊ាន; ២).កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី, ទាំងក្នុងក្របខណ្ឌតំបន់ និង ទ្វេភាគី; ៣).ផលលាភសន្តិភាព តាមរយៈការបន្តរក្សាបាននូវសុខសន្តិភាព និង ស្ថិរភាពនយោបាយ; ៤).ការអភិវឌ្ឍ និង ការពង្រឹងបានល្អ នូវតួនាទី និង ស្ថិរភាព នៃវិស័យហិរញ្ញវត្ថុ; ៥).ការអភិវឌ្ឍ និង ការពង្រឹងសមត្ថភាព នៃឧស្សាហកម្មគាំទ្រក្នុងស្រុក នៅក្នុងការបង្កើនតម្លៃបន្ថែម និង ការលើកកម្ពស់ភាពប្រកួតប្រជែងនៃវិស័យឧស្សាហកម្ម; ៦).ការចាប់យកប្រយោជន៍ពីផលលាភប្រជាសាស្ត្រ, វិស័យឌីជីថល និង វិស័យថ្មីៗ ដែលមានសក្តានុពល; និង ៧).ការជំរុញកិច្ចការកែទម្រង់ជារចនាសម្ព័ន្ធ និង ការរៀបចំយន្តការអនុវត្ត ឱ្យបានច្បាស់លាស់ និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដែលនឹងចូលរួមចំណែកយ៉ាងសំខាន់ ដល់ការជំរុញកំណើនសេដ្ឋកិច្ចក្នុងស្រុក ឱ្យមានសន្ទុះកាន់តែខ្លាំងក្លា ។

ច្បាស់ណាស់ថា នៅក្នុងបរិបទថ្មីនេះ, កម្ពុជាត្រូវសម្របជាប្រចាំ តាមនិន្នាការប្រែប្រួលសកល ដែលទាមទារនូវការយកចិត្តទុកដាក់ខ្ពស់ ចំពោះការលើកកម្ពស់ភាពជាអ្នកដឹកនាំ និង សមត្ថភាពស្ថាប័នគ្រប់កម្រិត ដោយផ្សារភ្ជាប់នឹងការធានាបាននូវគោលនយោបាយសមស្រប និង សមត្ថភាពអនុវត្តជាក់ស្តែង, លទ្ធផលការងារ និង ការទទួលខុសត្រូវ ដើម្បីឆ្លើយតបនឹងអាទិភាពសំខាន់ៗនៅក្នុងដំណាក់កាលថ្មី រួមមានជាអាទិ៍ ៖ ការពង្រឹងអភិបាលកិច្ច; ការទ្រទ្រង់កំណើន និង ការធ្វើទំនើបកម្មសេដ្ឋកិច្ច; ការបង្កើតការងារ, ទាំងគុណភាព និង បរិមាណ; ការលើកស្ទួយវិស័យឯកជន និង សហគ្រិនភាព; ការកសាងមូលធនមនុស្ស ដោយផ្តោតជាពិសេស លើគុណភាពវិស័យអប់រំ, សេវាសុខាភិបាល និង សីលធម៌សង្គម; ការលើកស្ទួយសេវាគាំពារសង្គម និង សុខុមាលភាពប្រជាជន, ជាពិសេស សម្រាប់គ្រួសារងាយរងហា-

និភ័យ និង ក្រុមជនងាយរងគ្រោះ; ការពង្រឹងគុណភាពនគរូបនីយកម្ម, ជាពិសេស ការកាត់-បន្ថយគម្លាតរវាងទីក្រុង និង ជនបទ; ការពង្រឹងចីរភាពបរិស្ថាន និង ការឆ្លើយតបទៅនឹងការ-ប្រែប្រួលអាកាសធាតុ; ព្រមទាំងការជំរុញធ្វើបរិវត្តកម្មឌីជីថល, ទាំងក្នុងសង្គម និង សេដ្ឋកិច្ច ។

នៅក្នុងក្របខណ្ឌនៃទស្សនវិស័យនេះ និង ផ្អែកតាម **កម្មវិធីនយោបាយ** របស់ខ្លួន, រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ស្វាហាប់ និង ឈ្លាស-វៃ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ដែលជាអគ្គមគ្គុទ្ទេសក៍វ័យក្មេងដ៏ឆ្នើម និង ពោរពេញដោយសមត្ថភាព, ចំណេះដឹង និង ថាមពល, បានដាក់ចេញ នូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ដើម្បីកំណើន, ការងារ, សមធម៌, ប្រសិទ្ធ-ភាព, និង ចីរភាព**, ដោយផ្តោតជាសំខាន់លើរបៀបវារៈ ជានា "**ប្រសិទ្ធភាពសមិទ្ធកម្ម**" តាម-រយៈការអនុវត្តអភិក្រម "**ឆ្លុះកញ្ចក់, ងូតទឹក, ដុសក្អែល, ព្យាបាល និង វះកាត់**" និង អភិក្រម "**ជរភាពនៃប្រព័ន្ធតួអង្គតែមួយ**" ។ ជាមួយនឹង**បាវចនា ៥** គឺ : **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និង ចីរភាព**, **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** បានកំណត់យក **អាទិភាពគន្លឹះ ៥** គឺ : "**មនុស្ស, ផ្លូវ, ទឹក, ភ្លើង,** និង **បច្ចេកវិទ្យា,** ជាពិសេស គឺ **បច្ចេកវិទ្យាឌីជីថល**" សម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី ៤ និង បរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និង សង្គមកម្ពុជា ក៏ដូចជាឆ្លើយតបនឹងតម្រូវការ ក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ដែលជាគ្រឹះ និង ជាមធ្យោបាយដ៏សំខាន់ នៃការសម្រេចបាននូវ **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** ។ លើសពីនេះ, ដើម្បីសម្រេចបានតាមគោលបំណងចម្បងរបស់ខ្លួន សំដៅ ៖ ម៉្យាង, បន្តរក្សាចលនការនៃសុខសន្តិភាព, កំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍ ជារួម; និង ម៉្យាងទៀត, កសាង និង ពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជំរុញសម្ទុះនៃការអភិវឌ្ឍប្រទេសជាតិ ឆ្ពោះទៅសម្រេចបាន **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០**; **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ក៏បានកំណត់ដាក់ចេញផងដែរនូវ **គោលដៅយុទ្ធសាស្ត្រជាក់លាក់ ចំនួន ៥** រួមមាន ៖

**(១).** ធានាឱ្យបានកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយភាពធន់នឹងវិបត្តិនានា;

**(២).** បង្កើតការងារឱ្យបានកាន់តែច្រើន, ទាំងបរិមាណ និង គុណភាព, ជូនដល់ប្រជា-ជនកម្ពុជា, ជាពិសេស សម្រាប់យុវជន;

(៣). សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និង បន្តខិតខំទាញទម្លាក់អត្រានៃភាពក្រីក្រ ឱ្យស្ថិតនៅក្នុងកម្រិតជាអប្បបរមា;

(៤). បន្តពង្រឹងសមត្ថភាពអភិបាលកិច្ច និង លើកកម្ពស់គុណភាពស្ថាប័ន, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃសេវាសាធារណៈ ក៏ដូចជា បន្តពង្រឹងអភិបាលកិច្ចវិស័យឯកជន និង បន្តកិច្ចប្រឹងប្រែងលើកកម្ពស់បរិយាកាសអំណោយផលសម្រាប់ធុរកិច្ច, ការវិនិយោគ និង ពាណិជ្ជកម្ម; និង

(៥). ធានាចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង កសាងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ ។

## ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!

នៅក្នុងសុន្ទរកថាបើកអង្គសន្និសីទកាលពីព្រឹកមិញ, **សម្តេចធិបតី នាយករដ្ឋមន្ត្រី** បានគូសរំលេចឱ្យឃើញផងដែរ អំពីភាពសកម្ម និង ភាពបុរេសកម្ម របស់រាជរដ្ឋាភិបាល ក្នុងការដាក់ចេញនូវ កម្មវិធី, យន្តការ និង វិធានការដាក់លាក់នានា ជាបន្តបន្ទាប់ ក្នុងរយៈពេល ៣ ខែ កន្លងទៅ សំដៅប្រែក្លាយគោលនយោបាយ និង យុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល ឱ្យចេញជាលទ្ធផលជាក់ស្តែង ដើម្បីឆ្លើយតបទៅនឹងបំណងប្រាថ្នា និង ការរំពឹងទុក របស់ប្រជាជនកម្ពុជា, ដែលខ្ញុំសូមមិនអធិប្បាយឡើងវិញទៀតទេ ។ នាពេលនេះ, ខ្ញុំគ្រាន់តែចង់ជម្រាបជូនអង្គសន្និសីទបន្ថែមថា នៅក្នុងវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន លើកទី ១៩ កាលពីថ្ងៃទី ១៣ ខែវិច្ឆិកា កន្លងទៅ, **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ក៏បានសម្រេចដាក់ចេញផងដែរ នូវ «**កម្មវិធីលើកកម្ពស់ភាពប្រកួតប្រជែង, បង្កើនពិពិធកម្ម និង ពង្រឹងភាពធន់ ដើម្បីកំណើនសេដ្ឋកិច្ច នៅក្នុងបរិការណ៍សកល ដែលមានភាពមិនប្រាកដប្រជាខ្ពស់ សម្រាប់ឆ្នាំ ២០២៤-២០២៨**» ។ ជារួម, កម្មវិធីនេះ នឹងរួមបញ្ចូលនូវវិធានការកែទម្រង់ជាក់លាក់, មុតស្រួច និង លម្អិត ជាច្រើនបន្ថែមទៀត ដែលនឹងក្លាយជាចំណែកដ៏សំខាន់ នៃផែនការយុទ្ធសាស្ត្រសម្រាប់បម្រើឱ្យការឈានទៅសម្រេចបាន នូវចក្ខុវិស័យរយៈពេលមធ្យម និង រយៈពេលវែង របស់កម្ពុជា ។ ខ្ញុំដាក់ការរំពឹងទុកថា លទ្ធផលនៃកិច្ចពិភាក្សា និង ការ-

ផ្លាស់ប្តូរទស្សនៈយ៉ាងផុលផុស ក្នុងសន្និសីទនាថ្ងៃនេះ នឹងក្លាយជាធាតុចូលដ៏មានសារៈ-សំខាន់ សម្រាប់ការរៀបចំកម្មវិធីខាងលើ ផងដែរ ។

មួយវិញទៀត, ខ្ញុំយល់ស្របថា យើងត្រូវមានការប្រយ័ត្នប្រយែង និង ត្រូវថ្លឹងថ្លែងជានិច្ច រវាង, ម្ខាង, មធ្យោបាយដែលយើងជ្រើសរើសយកមកប្រើប្រាស់ ដើម្បីឈានទៅសម្រេចបាននូវគោលដៅដែលយើងចង់បាន; និង ម្ខាងទៀត, ផលវិបាកផ្សេងៗ ដែលអាចកើតចេញពីការអនុវត្ត ។ ដូចខ្ញុំបានគូសបញ្ជាក់ពីខាងដើម, គោលដៅរបស់រាជរដ្ឋាភិបាល គឺប្រែក្លាយកម្ពុជា ទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ ស្របតាម **បាវចនាទាំង ៥** នៃ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ពោលគឺ **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព, និង ចីរភាព** ។ ក្នុងន័យនេះ, ច្បាស់ណាស់ថា យើងទាំងអស់គ្នា ពិតជាមិនចង់សម្រេចបាននូវចក្ខុវិស័យរួមរបស់ជាតិ ដោយបំផ្លិចបំផ្លាញបរិស្ថាន រហូតមិនអាចស្តារឡើងវិញបាន ឬ ដោយមិនអើពើចំពោះភាពអ-សមធម៌ និង ភាពអយុត្តិធម៌នៅក្នុងសង្គម, ឬ អស្ថិរភាពផ្នែកម៉ាក្រូសេដ្ឋកិច្ច, ឬ វិបត្តិបំណុលសាធារណៈវ័ណ្ឌក នោះទេ ។

ក្នុងស្មារតីនេះ, ខ្ញុំយល់ថា កម្ពុជាពិតជាមានតម្រូវចាំបាច់ ក្នុងការកសាងនូវ **ភាព-ធន់ក្នុងវិស័យទាំង ៥** ដូចដែលរាជរដ្ឋាភិបាលបានគូសរំលេចយ៉ាងច្បាស់ នៅក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដើម្បីអាចសម្រេចគោលដៅរបស់ខ្លួនសម្រាប់ឆ្នាំ ២០៣០ ខាងមុខផង និង អាចបន្តបោះជំហានឆ្ពោះទៅសម្រេចគោលដៅខ្ពស់ជាងនេះ ក្នុងរយៈពេលវែងទៅមុខទៀតផង ក្នុងនោះរួមមាន ៖

**ទី១- ភាពធន់នៃស្ថាប័នសាធារណៈ** តាមរយៈការបន្តកែទម្រង់ស្ថាប័នរដ្ឋ ដោយផ្តោតការយកចិត្តទុកដាក់ លើការពង្រឹងសមត្ថភាព និង ប្រសិទ្ធភាព ក្នុងការអនុវត្តការងារ, ការសម្រិតសម្រាំងមន្ត្រីដែលមានសមត្ថភាពខ្ពស់ និង គុណវុឌ្ឍិល្អ ព្រមទាំងការលើកកម្ពស់ការទទួលខុសត្រូវ និង ភាពម្ចាស់ការ របស់ក្រសួង-ស្ថាប័ន ដើម្បីឈានទៅសម្រេចបាននូវរដ្ឋបាលសាធារណៈមួយដែលស្អាតស្អំ, ឆ្លាតវៃ និង មានសមត្ថភាពខ្ពស់ ។

**ទី២- ភាពធន់នៃសេដ្ឋកិច្ច** តាមរយៈការពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច និង ការលើកកម្ពស់ភាពប្រកួតប្រជែង ដោយផ្ដោតការយកចិត្តទុកដាក់ លើការធ្វើឱ្យប្រសើរឡើង នូវបរិយាកាសវិនិយោគ និង កិច្ចសម្រួលពាណិជ្ជកម្ម; ការជំរុញឌីជីថលូបនីយកម្ម, ទាំងវិស័យសាធារណៈ និង វិស័យឯកជន; និងជាពិសេស ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត, ប្រព័ន្ធឡូជីស្ទីក, ថាមពលបៃតង និង ឌីជីថល ប្រកបដោយគុណភាពខ្ពស់ ។

**ទី៣- ភាពធន់នៃសង្គម និង ប្រជាជន** តាមរយៈការបន្តអភិវឌ្ឍប្រព័ន្ធសុខាភិបាល និង ប្រព័ន្ធគាំពារសង្គម, ទាំងគុណភាព និង វិសាលភាព, ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងវិបត្តិ ឬ ហានិភ័យនានា ដែលអាចកើតឡើងជាយថាហេតុ នាអនាគត ព្រមទាំងការបន្តអភិវឌ្ឍធនធានមនុស្ស ដោយផ្ដោតការយកចិត្តទុកដាក់ លើការពង្រឹងគុណភាពនៃវិស័យអប់រំ និង ការបណ្ដុះបណ្ដាលជំនាញបច្ចេកទេស ។ នៅត្រង់ចំណុចនេះ, ខ្ញុំសូមគូសរំលេចបន្ថែមថា អភិក្រមចំពោះការអភិវឌ្ឍ ដែលរាជរដ្ឋាភិបាលប្រកាន់យក គឺជាការអភិវឌ្ឍប្រកបដោយបរិយាបន្ន និង សមធម៌ ដែលមានការបែងចែកផ្លែផ្កានៃកំណើនសេដ្ឋកិច្ច ដល់ប្រជាពលរដ្ឋគ្រប់ស្រទាប់ ហើយក៏ជាការអភិវឌ្ឍ ដែលធ្វើឱ្យមានភាពប្រសើរឡើង ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និង សហគមន៍ នៅក្នុងការណ៍ជាក់ស្ដែង ពោលគឺ មិនមែនជាការណ៍គ្រាន់តែឆ្លុះបញ្ចាំងតាមរយៈតួលេខកំណើននៃផសស ប៉ុណ្ណោះទេ ។

**ទី៤- ភាពធន់នៃប្រព័ន្ធហិរញ្ញវត្ថុ** តាមរយៈការបន្តអភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន និង សុវត្ថិភាព; និង ការកែទម្រង់ប្រព័ន្ធថវិកាជាតិ, ទាំងផ្នែកចំណូល និង ផ្នែកចំណាយ, ឱ្យកាន់តែមានប្រសិទ្ធភាព ពិពិធភាព និង ចីរភាព ដោយរួមបញ្ចូលផងដែរ នូវការកសាងទ្រនាប់ថវិការឹងមាំ និង ការពង្រឹងប្រសិទ្ធភាព និង ចីរភាព នៃការគ្រប់គ្រងបំណុលសាធារណៈ; ដើម្បី, ម៉្យាង, ធានាឱ្យកម្ពុជាអាចត្រៀមខ្លួនបានយ៉ាងប្រសើរ ក្នុងការឆ្លើយតបតាមការចាំបាច់ ទៅនឹងការប្រែប្រួលនៃស្ថានភាពសង្គម-សេដ្ឋកិច្ច; និង ម៉្យាងទៀត, ធានាដល់ការទ្រទ្រង់ និង ការជំរុញលើកកម្ពស់សកម្មភាពសេដ្ឋកិច្ចទាំងមូល ឱ្យសម្រេចបានកំណើនខ្ពស់ ប្រកបដោយបរិយាបន្ន, ចីរភាព និង ភាពធន់ ។

*[សូមផ្ទៀងផ្ទាត់ តាមការអាន]*

**ទី៥- ភាពធន់នៃបរិស្ថាន និង អាកាសធាតុ** តាមរយៈការបង្កើនសមត្ថភាព ក្នុងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និង ការត្រៀមលក្ខណៈសម្បត្តិសមស្រប ដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយធម្មជាតិផ្សេងៗ ។

**ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!**

មុននឹងបញ្ចប់, ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និង សូមវាយតម្លៃខ្ពស់ ចំពោះការចូលរួមពិភាក្សាយ៉ាងសស្រាក់សស្រាំ របស់ **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក** និង **លោកស្រី** ។ ដូចបានរំលឹកពីខាងលើ, ខ្ញុំរំពឹងថា លទ្ធផលនៃការពិភាក្សានាថ្ងៃនេះ នឹងក្លាយជាធាតុចូលដ៏សំខាន់សម្រាប់រាជរដ្ឋាភិបាល ក្នុងការរៀបចំក្របខណ្ឌគោលនយោបាយ និង យុទ្ធសាស្ត្រអភិវឌ្ឍជាតិ សំដៅឈានទៅសម្រេចចក្ខុវិស័យរបស់កម្ពុជា ឆ្នាំ ២០៣០ និង សម្រាប់រយៈពេលវែងទៅមុខទៀត ដោយឈរលើអភិក្រម **«រួមគ្នាគិត, រួមគ្នាអនុវត្ត និង រួមគ្នាទទួលខុសត្រូវ»** ដើម្បីជោគវាសនាដ៏រុងរឿងរបស់ប្រជាជាតិកម្ពុជាទាំងមូល ។ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ និង ប្រកបដោយសមត្ថភាព, ថាមពល, ជវភាព និង ចំណេះដឹងដ៏សម្បូរបែប របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា, ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៣០** ក៏ដូចជា **ចក្ខុវិស័យកម្ពុជា ឆ្នាំ ២០៥០** នឹងប្រែក្លាយជាការពិតជាក់ជាមិនខានឡើយ, ដែលសមនឹងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាជនកម្ពុជា ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី, និង ភ្ញៀវកិត្តិយសទាំងអស់,** បានប្រកបដោយសុខភាពល្អបរិបូរណ៍, កម្លាំងមាំមួន និង សម្រេចបានជោគជ័យដ៏ត្រចះត្រចង់ក្នុងគ្រប់ភារកិច្ច ព្រមទាំងទទួលបាននូវវិបុលភាព និង សុភមង្គល ក្នុងក្រុមគ្រួសាររៀងៗខ្លួន នៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព ។

ខ្ញុំសូមប្រកាសបិទ **សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ ២០២៣** នាពេលនេះ ៕

***សូមអរគុណ!***